


President's New Year's Guidance

# មួយឆ្នាំដ៏ថ្មីស្រឡាង

ព្រះគ្រូនីវ៉ាណូនីជីកុ
ព្រះប្រធានសមាគមរីហ្សូកូសេកៃ



**ខ្ញុំព្រះករុណាអាត្មាភាពគិតថាគ្មានអ្វីដែលសំខាន់ជាងការបណ្តុះបណ្តាលមនុស្សឡើយ ដូច្នេះឆ្ពោះទៅរកខួបលើកទី ១០០ នៃការបង្កើតសមាគមរបស់យើង យើងត្រូវខិតខំប្រឹងប្រែងអស់ពីសមត្ថភាពទៅលើការងារបណ្តុះបណ្តាលមនុស្សនេះបន្តទៅទៀត។**

សួស្តីឆ្នាំថ្មី។

ថ្ងៃថ្មីពេញមួយថ្ងៃដែលយើងទទួលមុនគេបង្អស់នៅដើមឆ្នាំក្រោយថ្ងៃចុងក្រោយគេនៃឆ្នាំចាស់នេះគឺជាថ្ងៃដំបូងដែលមិនអាចមានអ្វីមកជំនួសបាន ចាប់តាំងពីយើងកើតមក។មិនថាអ្នកមានអាយុប៉ុន្មានទេចាប់ពីថ្ងៃនេះទៅថ្ងៃខាងមុខមួយថ្ងៃៗគឺជាបទពិសោធន៍ថ្មីស្រឡាងសម្រាប់យើងក្នុងជីវិត។

នៅក្នុងអក្សរសាស្ត្រចិនបុរាណមានអក្សរសិល្ប៍តន្ត្រីមួយដែលមានចំណងជើងថា"សាកលវិទ្យាល័យ"។ នៅក្នុងសៀវភៅនោះមានពាក្យមួយឃ្លាថា "កាន់តែល្អប្រសើរទៅពីមួយថ្ងៃទៅមួយថ្ងៃ"។ មានការនិទានថាមានព្រះអង្គម្ចាស់ដ៏ល្បីល្បាញមួយអង្គនៅប្រទេសចិនបុរាណបានឆ្លាក់ពាក្យទំនៀមនេះលើចានដែកដែលព្រះអង្គប្រើសម្រាប់លុបមុខ ហើយសូត្រឃ្លា

នេះជារៀងរាល់ថ្ងៃដើម្បីជាស់តឿនខ្លួនព្រះអង្គ។

យើងទាំងអស់គ្នាក៏ចង់ធ្វើឱ្យឆ្នាំនេះទៅជាឆ្នាំមួយដែលយើងមានកម្លាំងមាំមួនអាចធ្វើការងារជារៀងរាល់ថ្ងៃ ប្រកបដោយមានភាពរស់រវើកនិងថាមពលដែរ។

ឥឡូវនេះ នៅក្នុងកិច្ចប្រជុំថ្នាក់លើនៃសមាគមកាលពីខែវិច្ឆិកាឆ្នាំមុន ខ្ញុំព្រះករុណាអាត្មាភាពបានបង្ហាញពី "គោលការណ៍សម្រាប់ឆ្នាំ២០២៥" ដូចខាងក្រោមនេះ

"មនុស្សយើងមិនត្រូវស្ថិតនៅតែក្នុងការពិតទេ ប៉ុន្តែត្រូវស្វែងរកអ្វីដែលនៅខ្ពស់ហៅមិនឮ ឬអ្វីមួយដែលមានតម្លៃ អ្វីមួយដែលអស្ចារ្យ។ ពេលធ្វើបែបនេះអ្វីដែលកើតឡើងគឺយើងទទួលបាននូវស្មារតីនៃការគោរព។នៅពេលដែលស្មារតីនៃការគោរពនេះរីកចម្រើនឡើងយើងក៏មើលមកឃើញខ្លួនយើងស្ថិតនៅក្នុងការពិតមានកម្រិតទាបតូចហើយក៏មានចិត្តអៀនខ្មាស។ អ្វីដែលសំខាន់បំផុតសម្រាប់មនុស្សដើម្បីកែលម្អ គឺអភិវឌ្ឍអារម្មណ៍នៃការគោរព និងរៀនឱ្យមានអារម្មណ៍ចេះអៀនខ្មាស"។

ផ្អែកលើស្មារតីសំខាន់ដែលបង្ហាញដោយពាក្យដ៏ត្រឹមត្រូវបំផុតរបស់បុព្វបុរសរបស់យើងខាងលើនេះ នៅឆ្នាំនេះផងដែរយើងនឹងបន្តការអធិស្ឋានសម្រាប់គ្នាទៅវិញទៅមកក្នុងនាមប្តីនិងប្រពន្ធជាឪពុកម្តាយ ជាជីដូនជីតា និងដើម្បីកូនចៅនិងយុវជនដែលនឹងទទួលខុសត្រូវលើអនាគតប្រទេសជាតិរបស់យើង តាមរយៈជីវភាពរាល់ថ្ងៃដែលមានជំនឿលើព្រះពុទ្ធសាសនា។ ចូរយើងធ្វើការយ៉ាងសកម្មជារៀងរាល់ថ្ងៃ ដើម្បីណែនាំប្រជាជនរបស់យើង និងអភិវឌ្ឍពួកគេឱ្យក្លាយជាមនុស្ស អាចរៀបចំគ្រួសារឱ្យមត់មូលជុំគ្នា និងបន្តមរតកប្រពៃ ណីរបស់ប្រទេសជាតិដើម្បីកសាងប្រទេសដ៏ល្អមួយ។

ខ្លឹមសារគឺស្ទើរតែដូចគ្នាទៅនឹងឆ្នាំមុនដែរ ប៉ុន្តែវាជាកត្តាសំខាន់ដែលយើងគួរចងចាំទុកជានិច្ចក្នុងនាមជាសមាជិកនៃសមាគមនេះ។



រហូតមកដល់ពេលនេះ ខ្ញុំព្រះករុណាអាត្មាភាពបាននិយាយថា យើងគួរតែប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីសម្រេចបាននូវបេសកកម្មជាមូលដ្ឋានសម្រាប់ "ការបណ្តុះបណ្តាល (កសាង) មនុស្ស"។

សៀវភៅទស្សនវិជ្ជាចិនបុរាណគ័នស៊ី (Guanzi) ចែងថា "ប្រសិនបើអ្នកមានគម្រោងរយៈពេលមួយឆ្នាំ ចូរអ្នកដាំគ្រាប់ធញ្ញជាតិ ប្រសិនបើអ្នកមានគម្រោងរយៈពេលដប់ឆ្នាំ ចូរអ្នកដាំដើមឈើ។ ប្រ សិនបើអ្នកមានគម្រោងសម្រាប់មួយជីវិត គ្មានអ្វីប្រ សើរជាងការដាំបណ្តុះបណ្តាលមនុស្សនោះទេ"។ ប្រសិនបើយើងគិតពីអនាគតនៃសហគមន៍មូលដ្ឋាន ប្រទេសជាតិ និងពិភពលោកនោះ អ្វីដែលសំខាន់បំផុតនោះគឺការអភិវឌ្ឍន៍មនុស្ស។

មូលដ្ឋាននៃការអភិវឌ្ឍន៍នេះគឺស្ថិតនៅលើការអប់រំក្នុងគ្រួសារ។ យោលទៅតាមការរៀបចំមូលដ្ឋានគ្រួសារឱ្យបានរឹងមាំ ការអប់រំរបស់មនុស្សក៏បានរឹងមាំហើយការអប់រំនៅសាលាក៏នឹងកាន់តែបានពេញលេញហើយកត្តានេះបន្តផ្ជាប់ទៅនឹងន័យពិតនៃពាក្យ "ការដាំបណ្តុះមនុស្ស" ។

សាស្ត្រាចារ្យម៉ាសាអាតស៊ឺ យ៉ាស៊ឺអូកា (Masaatsu Yasuoka) ដែលគេស្គាល់ថាជាស្ថាបនិកនៃទស្សនវិជ្ជាបូព៌ាបានសរសេរនៅក្នុងសៀវភៅរបស់លោកថា "ឪពុកចង់ក្លាយជាកម្មវត្ថុនៃការគោរពរបស់កូនៗ ឯម្តាយចង់ធ្វើជាទីកន្លែងនៃក្តីស្រឡាញ់របស់កូនៗ។ មូលហេតុគឺដោយសារតែមានពាក្យថាគ្រួសារគឺជាថ្នាលសម្រាប់បណ្តុះបណ្តាលកូនៗ" ។ ប្រសិនបើមិនបានរៀបចំថ្នាលសម្រាប់សាបព្រោះឱ្យបានល្អទេ សំណាបក៏មិនអាចដុះលូតលាស់ល្អហើយក៏គ្មានសង្ឃឹមថាអាចប្រមូលផលនៅរដូវលំហើយបានដែរ។

មនុស្សធម៌របស់កុមារ និងយុវជននឹងត្រូវបានពង្រឹងប្រសិនបើរៀមច្បងនៃជីវិត ដូចជាប្តីនិងប្រពន្ធ (ក្មេងជំនាន់ក្រោយ) ឪពុកម្តាយ (មនុស្សវ័យ ចំណាស់) និងជីដូនជីតា (មនុស្សចាស់) បំពេញតួនាទីរៀងៗខ្លួនដែលជាចំណុចចាប់ផ្តើម សម្រាប់ការអភិវឌ្ឍន៍មនុស្ស។ឆ្ពោះទៅរកខួបលើកទី ១០០ នៃការបង្កើតសមាគមរបស់យើងខ្ញុំព្រះករុណាអា ត្មាភាពសង្ឃឹមយ៉ាងមុតមាំថា យើងនឹងខិតខំប្រឹងប្រែងលើការបណ្តុះបណ្តាលមនុស្សបន្តទៅទៀត។

ម្យ៉ាងទៀត ព្រះអង្គម្ចាស់ Shotoku ធ្លាប់បានបញ្ចូលឃ្លាថា "ភាពសុខដុមរមនា បង្កើតសេចក្តីថ្លៃថ្នូរ" ទៅក្នុងមាត្រាដំបូងនៃរដ្ឋធម្មនុញ្ញ ១៧ មាត្រា។ យោលទៅតាមប្រវត្តិសាស្ត្រ ប្រទេសជប៉ុនពីដើមមានឈ្មោះថា "យ៉ាម៉ាតូ" (ដែលសរសេរជាអក្សរចិនថាសន្តិភាពដ៏ធំ) ហើយរក្សាស្មារតីនៃ "សន្តិភាពដ៏ធំ" និង "ភាពសុខដុមរមនាដ៏អស្ចារ្យ"មកធ្វើជាមូលដ្ឋានគ្រឹះនៃការកសាងប្រទេសជាតិ។ ទំនៀមទម្លាប់របស់ជនជាតិជប៉ុនទាំងនេះត្រូវបានចែករំលែកទៅទូទាំងពិភពលោក ហើយវាជាតួនាទីសំខាន់របស់យើងជាជប៉ុនក្នុងការខិតខំធ្វើឱ្យកត្តានេះបានសម្រេចទៅជាការពិត។

## រឿងសំខាន់នៃការគោរពគឺអាត្មាអញត្រូវគោរពអាត្មាអញហើយខ្លួនឯងត្រូវគោរពខ្លួនឯង។

លើសពីនេះ "ស្មារតីនៃការគោរព" នៅក្នុងគោលនយោបាយនៅឆ្នាំនេះ មានន័យថាមានគោលដៅដ៏ធំអស្ចារ្យ និងបំណងប្រាថ្នាឱ្យមានវឌ្ឍនភាព និងការកែលម្អ។ គឺជាចិត្តដែលខិតខំឈានទៅរកទីខ្ពង់ខ្ពស់ទោះជាតែបន្តិចក៏ដោយៗសារតែដឹងថាខ្លួនមិនទាន់ពេញលេញមិនទាន់គ្រប់គ្រាន់នៅឡើយ ។

នៅពេលដែលការគោរពបែបនេះបានលូតលាស់ យើងក៏អាចក្រឡេកបែរក្រោយមើលចំណុចខ្វះខាតរបស់យើង ហើយមានអារម្មណ៍ខ្មាសអៀន។ បន្ទាប់មកដោយការដាស់តឿនខ្លួនឯង និងតម្រែតម្រង់ខ្លួនឯង យើងក៏បង្កើនការសម្រួមហើយការខិតខំនិងសេចក្តីព្យាយាមថ្មីនឹងចាប់ផ្តើម។

ចំពោះការគោរពនេះមានកត្តាសំខាន់បំផុតដែលត្រូវដឹង។ពោលគឺថា រឿងសំខាន់នៃការគោរពគឺអាត្មាអញត្រូវគោរពអាត្មាអញហើយខ្លួនឯងត្រូវគោរពខ្លួនឯង។

មនុស្សដែលមិនទទួលស្គាល់សេចក្តីថ្លៃថ្នូររបស់ខ្លួនឯងមិនអាចគោរពអ្នកដទៃបានយ៉ាងពិតប្រាកដទេ។ មានតែបុគ្គលដែលស្គាល់សេចក្តីថ្លៃថ្នូររបស់ខ្លួនប៉ុណ្ណោះ ទើបអាចយល់ដឹងពីសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ។

អប់រំវិទូគីសាស្ត្រាចារ្យ យោស៊ីអូ ហ៊ីង៉ាស៊ី (Yoshio Higashii) បានប្រើពាក្យថាវាពិតជាអព្ភូតហេតុដែលពួកយើងបានទទួលជីវិតចូលមកក្នុងពិភពលោកនេះ ។

"គ្មាននរណាម្នាក់កើតមកក្នុងពិភពលោកនេះតាមឆន្ទៈរបស់ខ្លួនទេ។ មនុស្សគ្រប់រូបត្រូវបាននាំ

នាំយកមកក្នុងពិភពលោកនេះដោយកម្លាំងដែលគ្មាននរណាស្គាល់។គឺជាជីវិតនិងឆាកជីវិតដែលបានផ្តល់ដល់យើង" ។

គឺជាពាក្យដែលប៉ះទង្គិចបេះដូងខ្ញុំព្រះករុណាអាត្មាភាពយ៉ាងខ្លាំង។

ទន្ទឹមនឹងនេះដែរ ជីវិតរបស់យើងម្នាក់ៗពឹងផ្អែកលើគុណបុណ្យនៃសកលលោកទាំងមូល រួមមានព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ ភ្នំ ទន្លេ ខ្យល់ និងទឹក ព្រមទាំងមនុស្សជុំវិញខ្លួនយើង សត្វ រុក្ខជាតិ សត្វល្អិត អតិសុខុមប្រាណនិងបាក់តេរី។

កាលណាខ្ញុំព្រះករុណាអាត្មាភាពក្រឡេកមើលជីវិតខ្លួនឯងពេលណាពេលនោះខ្ញុំព្រះករុណាអាត្មាភាពកាន់តែមានការភ្ញាក់ផ្អើលចំពោះភាពថ្លៃថ្លា ភាពអស្ចារ្យនិងការដឹងគុណចំពោះអ្វីទាំងនេះ។

សំខាន់ជាងនេះទៅទៀតគេបានបង្រៀនយើងទាំងអស់គ្នាថាមនុស្សទាំងអស់កើតមកសុទ្ធតែមានសមត្ថភាពក្នុងការត្រាស់ដឹងដូចព្រះពុទ្ធ និងមានលទ្ធភាពអាចដឹងពីគោលការណ៍នៃសច្ចធម៌ ហើយទទួលបានគ្រាប់ពូជដែលអាចក្លាយជាព្រះពុទ្ធ ពោលគឺថាមានធាតុជាព្រះពុទ្ធនៅក្នុងខ្លួនជាស្រេច។

នៅពេលអ្នកឃើញនរណាម្នាក់មានបញ្ហា អារម្មណ៍ចង់ជួយពួកគេតាមមធ្យោបាយណាមួយក៏កើតឡើងដែលបង្ហាញថាអ្នកមានបំណងប្រាថ្នាដ៏ជ្រៅនៅក្នុងចិត្តរបស់អ្នកដូចគ្នាទៅនឹងព្រះពុទ្ធដែរ ។

ជារៀងរាល់ថ្ងៃយើងលើកដៃថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ។ យើងមានចិត្តដូចព្រះពុទ្ធដែរ។ ការថ្វាយបង្គំព្រះពុទ្ធគឺដូចគ្នានឹងការថ្វាយបង្គំធាតុជាព្រះពុទ្ធដែលនៅក្នុងខ្លួនយើងដែរ។ដូច្នេះការថ្វាយបង្គំព្រះពុទ្ធគឺការថ្វាយបង្គំធាតុជាព្រះពុទ្ធដែលនៅក្នុងខ្លួនយើង។

ក៏ប៉ុន្តែ យើងទាំងអស់គ្នាម្នាក់ៗសុទ្ធតែមានអំណោយជាព្រលឹង គឺជីវិតដ៏មានតម្លៃដែលអាចហៅថាអច្ឆរិយៈ។ យើងមានធាតុជាព្រះពុទ្ធដូចព្រះពុទ្ធនៅក្នុងចិត្ត។ បុគ្គលម្នាក់ៗក៏មានសមត្ថភាពអាចដឹងសច្ចធម៌ និងធម៌ព្រះពុទ្ធ ក៏ដូចជាសមត្ថភាពក្នុងការដោះស្រាយបញ្ហាដោយខ្លួនឯងផងដែរ។ ការរក្សានូវចំណុចទាំងនេះទុក



ក្នុងចិត្ត ហើយព្យាយាមប្រឹងប្រែងដោយភាពជឿជាក់ គឺជាមូលដ្ឋាននៃជីវិតដែលមានមូលដ្ឋានផ្អែកលើធម៌ព្រះពុទ្ធ។

ព្រះគ្រូដូហ្គេន (Dogen Zenji) ដែលជាស្ថាបនិកនៃពុទ្ធសាសនានិកាយ សូតូស៊ូ បានមានសង្ឃដីកាថា "ជីវិតដែលយើងរស់នៅសព្វថ្ងៃនេះគឺជាជីវិតដ៏មានតម្លៃ និងជានិមិត្តសញ្ញាដ៏មានតម្លៃ។ យើងត្រូវតែស្រឡាញ់រាងកាយ និងចិត្តរបស់យើង ហើយយើងក៏ត្រូវតែគោរពខ្លួនឯងផងដែរ។"

ជីវិតមួយថ្ងៃនេះជាជីវិតដ៏គួរឲ្យគោរព។ ជារូបកាយដែលគួរឱ្យគោរព។ មានន័យថាអ្នកគួរតែស្រឡាញ់ និងគោរពទាំងកាយនិងទាំងចិត្តរបស់អ្នកដែលព្យាយាមប្រតិបត្តិព្រះពុទ្ធសាសនា។

យើងគួរតែចាប់ភ្លឹកនិងដឹងខ្លួនដឹងថាខ្លួនត្រូវតែគោរពបេះដូង និងរាងកាយរបស់ខ្លួនដែលយកចិត្តទុកដាក់ក្នុងការសិក្សានិងអនុវត្តមាគ៌ាព្រះពុទ្ធសាសនា។

## នៅថ្ងៃទី ២០ ខែមីនាឆ្នាំនេះខ្ញុំព្រះករុណាអាត្មាភាពមានអាយុ ៨៧ ឆ្នាំចូល ៨៨ ឆ្នាំដែលជប៉ុនគេហៅថា "Beiju" ។

ជាជីវិតដែលព្រះ និងព្រះពុទ្ធបានប្រោសប្រទានឱ្យខ្ញុំព្រះករុណាអាត្មាភាព ហើយខ្ញុំព្រះករុណាអាត្មាភាពសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដែលអនុញ្ញាតិឱ្យខ្ញុំព្រះករុណាអាត្មាភាពរស់នៅដល់ថ្ងៃនេះ ក៏គឺដោយសារតែការជួយឧបត្ថមពីអ្វីៗទាំងអស់ពីមេឃ និងផែនដី។

ឪពុកម្តាយរបស់មនុស្សម្នាក់មានមនុស្សពីរនាក់ ប៉ុន្តែប្រសិនបើអ្នកត្រឡប់ក្រោយទៅ ៣០ ជំនាន់មុន គឺទៅដល់ជំនាន់ជីដូនជីតាជីតួតជីលួតជីលាយើង ដែលគេនិយាយថាមានជាង១ពាន់លាននាក់នោះ គឺដោយ សារបុព្វបុរសជាច្រើនឥតគណនាទាំងនោះ បានបន្តរហូតមកគ្មានដាច់នោះឯង។

នៅក្នុងខ្សែសង្វាក់ជីវិតដ៏អស់កល្បនេះព្រះស្ថានិកទទួលមរណៈភាពនៅព្រះជន្មាយុ ៩២ វស្សា ដោយរស់នៅទៅតាមសមាជីវោរបស់ព្រះអង្គ។ ម្តាយរបស់ខ្ញុំព្រះករុណាអាត្មាភាពក៏បានរស់នៅពេញមួយជីវិតរបស់គាត់ក្នុងនាមជាម្តាយហើយទទួលមរណៈភាពនៅអាយុ ៨៥ ឆ្នាំ។ក្នុងន័យនេះ ខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថា យើងម្នាក់ៗកំពុងតែហុចដំបងនៃការរត់ប្រណាំងបណ្តាក់នៃជីវិតទៅឱ្យអ្នកបន្តវេនគេកាន់រត់បន្តពីយើងហើយ។គឺថា មនុស្សម្នាក់ៗជាកីឡាកររត់បណ្តាក់មានភារកិច្ចនឹងខំរត់ចម្ងាយដែលគេផ្តល់មកឱ្យខ្លួនរៀងៗខ្លួន។

ប្រសិនបើអ្នកប្រៀបធៀបវាទៅនឹងការហែលទឹកវិញ កីឡាករម្នាក់ៗមានអត្តចរិតខុសគ្នាវាដូចជាការប្រកួតមេឌីឡេរីឡេ (Medley relay) ដែរ។ មនុស្សខ្លះពូកែហែលផ្ងារខ្លះទៀតពូកែហែលបែបមេអំបៅ ឯអ្នកខ្លះទៀតពូកែហែលកង្កែបជាដើមដូច្នោះដែរ។

ក្នុងនាមជាសមាជិកនៃការរត់បណ្តាក់ឬ អ្នកហែលទឹកប្រកួតមេឌីឡេរីឡេ (Medley relay) ម្នាក់ៗបន្តហែលទឹកក្នុងចម្ងាយដែលបានផ្តល់ឱ្យអស់ពីសមត្ថភាពរបស់ពួកគេ។ នៅទីបំផុត គេហុចដំបងទៅអ្នកបន្ទាប់ គឺកូន ឬចៅ។ ខ្ញុំព្រះករុណាអាត្មាភាពយល់ថានេះជារបៀបប្រព្រឹត្តទៅនៃជីវិត។

ពេលចាស់ទៅ អ្នកមិនអាចធ្វើអ្វីបានដូចមនុស្សក្មេងទេ។ ជើង និងចង្កេះរបស់អ្នកក៏ចុះខ្សោយដែរ។ ក៏ប៉ុន្តែខួរក្បាលរបស់អ្នកបើអ្នកប្រើវាកាន់តែច្រើនវានឹងរឹតតែឡើងប្រសើរ។

លោកសាតូ អ៊ីស្សៃ (Sato Issai) អ្នកប្រាជ្ញខាងវិទ្យាខុងជឺពីចុងសម័យអេដូបានលើកឡើងថា៖ "បើរៀនពេលអ្នកនៅក្មេង អ្នកនឹងអាចធ្វើរឿងអស្ចារ្យជាច្រើននៅពេលដែលអ្នកចាស់ទៅ ពេលអ្នកអាយុច្រើនទៅ បើអ្នករៀនច្រើនអ្នកនឹងមិនចេះចាស់ បើអ្នកចាស់ទៅហើយអ្នករៀនច្រើនអ្នកនឹងមិនទន់មិនចេះពុកមិនចេះរលួយ ហើយមិនស្លាប់"។

មានន័យថា ប្រសិនបើមនុស្សម្នាក់មិនឈប់រៀនសូម្បីតែមានអាយុចាស់ហើយក៏ដោយ ប្រជាប្រិយភាព និងកេរ្តិ៍ដំណែលខាងវិញ្ញាណរបស់ពួកគេនឹងមិនសាបសូន្យឡើយ ហើយនឹងត្រូវបន្តទៅមនុស្សជំនាន់ក្រោយ ទោះបីជាជីវិតរបស់ពួកគេបានបញ្ចប់ទៅហើយក៏ដោយ។

អ្វីដែលសំខាន់បំផុតគឺសទ្ធាថា និងរៀនសូត្រដើម្បីជួយអ្នកដទៃ និងនាំសន្តិភាពដល់ពិភពលោក។គេថាកាលណាមនុស្សរៀនសូត្រ ចិត្តគេក៏ភ្លឺថ្លាដូចផ្កាយដែលភ្លឺចែងចាំង។



ក្នុងឆ្នាំនេះ ក៏ខ្ញុំព្រះករុណាអាត្មាភាពសូមសិក្សារៀនសូត្របន្តកក្រើកតទៅទៀតយ៉ាងសប្បាយរីករាយ និងអនុវត្តរួមគ្នាជាមួយអ្នកទាំងអស់គ្នា ដោយដើរលើវិថីព្រះពោធិសត្វ (មនុស្សធម៌) ដូចដែលព្រះសម្មាសម្ពុទ្ធសក្យមុនីគោត្តមលោកបានបង្ហាញ។